ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១១២៧ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦

# សេចក្តីណែនាំ
## ស្តីពីការប្រើប្រាស់វិក្កយបត្រ
## សម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស

អនុលោមតាមមាត្រា៧៧ មាត្រា៧៨ មាត្រា៧៩ និងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (អតប) ព្រមទាំងសេចក្តីជូនដំណឹងលេខ០២៤ សហវ-ពដ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) អ្នកជាប់ពន្ធទាំងអស់ត្រូវចេញវិក្កយបត្រលើរាល់ការលក់ ឬផ្គត់ផ្គង់ទំនិញឬសេវា ឱ្យបានត្រឹមត្រូវតាមគំរូដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ (គំរូវិក្កយបត្រទី១ ទី២ ទី៣ និងទី៤)។

ក្នុងការពង្រឹងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងការគ្រប់គ្រងចំណូលសារពើពន្ធឱ្យមានតម្លាភាពដើម្បីបង់ចូលថវិកាជាតិ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំអំពីវិធានប្រើប្រាស់វិក្កយបត្រដូចខាងក្រោម÷

**ក- វិក្កយបត្រត្រូវមាននិទ្ទេសសំខាន់ៗមួយចំនួន ដូចខាងក្រោម÷**

១- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្ម **អ.ត.ប (VATTIN)** របស់សហគ្រាសជាអ្នកលក់ ឬអ្នកផ្គត់ផ្គង់

២- ត្រូវមានលេខរៀងវិក្កយបត្រតាមលំដាប់ និងត្រូវមានកាលបរិច្ឆេទចេញវិក្កយបត្រ ឱ្យបានច្បាស់លាស់

៣- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញ ព្រមទាំងលេខអត្តសញ្ញាណកម្ម អ.ត.ប ប្រសិនបើអ្នកទិញជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

៤- សេចក្តីបរិយាយ បរិមាណ និងថ្លៃលក់ទំនិញ ឬសេវា

៥- តម្លៃសរុបដែលមិនទាន់គិតអាករ និងប្រាក់អាករដាច់ដោយឡែក

៦- គុណភាពទឹកថ្នាំបោះពុម្ពលើវិក្កយបត្រ និងសន្លឹកក្រដាសវិក្កយបត្រ ត្រូវតែរក្សាទុកបានយូរ។

ខ- រាល់វិក្កយបត្រ ត្រូវសរសេរ ឬបោះពុម្ពជាភាសាខ្មែរ ឬអាចជាពីរភាសា គឺភាសាខ្មែរនិងភាសាអង់គ្លេស ហើយដែលភាសាអង់គ្លេស ត្រូវនៅពីក្រោមភាសាខ្មែរ

គ- ត្រូវចេញវិក្កយបត្រអាករ (Tax Invoice) រាល់ការផ្គត់ផ្គង់ទំនិញ ឬសេវាទាំងអស់ ដល់អតិថិជនជាបុគ្គលជាប់អាករ ឬចេញវិក្កយបត្រធម្មតា (Commercial Invoice) ដល់អតិថិជនដែលមិនមែនជាបុគ្គលជាប់អាករ

ឃ- អ្នកជាប់ពន្ធត្រូវប្រើប្រាស់វិក្កយបត្រតាមលំដាប់លេខរៀងពេញមួយឆ្នាំ និងត្រូវរក្សាទុកជាឯកសារ សម្រាប់គោលដៅពន្ធដារ រយៈពេល ១០ ឆ្នាំ

ង- ចំពោះវិក្កយបត្រមិនត្រឹមត្រូវតាមទម្រង់ដូចមានកំណត់ក្នុងសេចក្តីណែនាំនេះ គឺមិនត្រូវបានអនុញ្ញាតឱ្យយកមកប្រើប្រាស់ជាឥណទានអាករលើធាតុចូល (VAT Credit) និងមិនត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងជាចំណាយសម្រាប់គណនាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំទេ។ រាល់ការស្នើសុំឥណទានអាករលើធាតុចូល (VAT Credit) ប្រចាំខែ ត្រូវភ្ជាប់មកជាមួយនូវវិក្កយបត្រអាករត្រឹមត្រូវ ឬជាឯកសារស្កេន (Scan) ចេញពីច្បាប់ដើម (Soft Copy)។ ដូចគ្នានេះដែរ ចំពោះរាល់ការស្នើសុំកាត់កងចំណាយ ក៏ត្រូវមានវិក្កយបត្រត្រឹមត្រូវ ដូចមានកំណត់ក្នុងសេចក្តីណែនាំនេះផងដែរ។

ច- អំពីគំរូវិក្កយបត្រ

វិក្កយបត្រអាករលើតម្លៃបន្ថែម (Tax Invoice) ត្រូវរចនាស្របតាមគំរូវិក្កយបត្រទាំងបួនប្រភេទ ដូចភ្ជាប់ជូនក្នុងឧបសម្ព័ន្ធនេះ។

- គំរូវិក្កយបត្រទី១ និងទី២ ប្រើសម្រាប់ការសរសេរវិក្កយបត្រដោយដៃ ឬបោះពុម្ពដោយប្រព័ន្ធកុំព្យូទ័រ។ គំរូវិក្កយបត្រ ទី៣ និងទី៤ គឺប្រើសម្រាប់ការចេញវិក្កយបត្រដោយម៉ាស៊ីនគិតលុយ (POS) ឬម៉ាស៊ីនគិតលុយតាមប្រព័ន្ធកុំព្យូទ័រ។
- គំរូវិក្កយបត្រទី១ និងទី៣ ប្រើសម្រាប់បុគ្គលជាប់អាករលើតម្លៃបន្ថែម (អ.ត.ប) ចេញឱ្យអតិថិជនរបស់ខ្លួនដែលជាបុគ្គលជាប់អាករលើតម្លៃបន្ថែម។ វិក្កយបត្រគំរូទី១ និងទី៣ នេះ នឹងត្រូវប្រើប្រាស់សម្រាប់ស្នើសុំឥណទានអាករលើតម្លៃបន្ថែម និងសម្រាប់ជាកម្មវត្ថុនៃការកាត់កងចំណាយសម្រាប់គណនាពន្ធលើប្រាក់ចំណេញ។
- គំរូវិក្កយបត្រទី២ និងទី៤ ប្រើសម្រាប់អតិថិជនដែលមិនមែនជាបុគ្គលជាប់ អ.ត.ប ពោលគឺសម្រាប់អ្នកប្រើប្រាស់ចុងក្រោយ។ គំរូវិក្កយបត្រនេះ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ស្នើសុំឥណទានអាករលើតម្លៃបន្ថែម ឡើយ។

ឆ- អំពីទោសទណ្ឌ

ការមិនចេញវិក្កយបត្រ ឬបានចេញវិក្កយបត្រមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាអំពើរាំងស្ទះក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់ស្តីពីសារពើពន្ធ និងត្រូវរងនូវទោសទណ្ឌដូចមានចែងក្នុងមាត្រា១៣៣ និងមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ មានជាអាទិ៍ ការបិទអាជីវកម្មក្នុងមួយរយៈពេលដែលកំណត់ដោយច្បាប់, ការធ្វើការកំណត់ពន្ធឡើងវិញ ឬការប្តឹងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារដែលត្រូវទទួលរងការផ្តន្ទាទោសផាកពិន័យជាប្រាក់ដល់ ១០ ០០០ ០០០រៀល ឬជាប់ពន្ធនាគាររហូតដល់១ឆ្នាំ ឬទោសទាំងពីរនេះ។

ក្នុងការអនុវត្តច្បាប់ អគ្គនាយកដ្ឋានពន្ធដារនឹងចាត់មន្ត្រីពន្ធដារចុះដល់ទីតាំងរបស់សហគ្រាសតាមការជាក់ស្តែង ឬធ្វើការផ្ទៀងផ្ទាត់ (Cross Check) វិក្កយបត្រដែលចេញដោយសហគ្រាសផ្គត់ផ្គង់ទំនិញ ឬសេវា ដើម្បីពិនិត្យភាពត្រឹមត្រូវនៃការប្រើប្រាស់វិក្កយបត្ររបស់សហគ្រាស ដូចបានជម្រាបជូនខាងលើ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាម្ចាស់ និងជាបណ្ណាធិការនៃសហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ បានយ៉ាងខ្ជាប់ខ្ជួនប្រកបដោយតម្លាភាព និងស្មារតីទទួលខុសត្រូវ ព្រមទាំងកិច្ចសហការខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**

<u>កន្លែងទទួល៖</u>

- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពពន្ធដារពាក់ព័ន្ធ
  "ដើម្បីមុខការ"
- គ្រប់សហគ្រាសជាប់ពន្ធទាំងអស់
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

រូបសញ្ញារបស់ក្រុមហ៊ុន
LOGO

# ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ
## COMPANY NAME

លេខអត្តសញ្ញាណកម្ម អតប (VATTIN) □□□□-□□□□□□□□□

អាសយដ្ឋាន៖ Address | ផ្ទះលេខ N° | ផ្លូវ Street | ឃុំ/សង្កាត់ Commune/Sangkat

ក្រុង/ស្រុក/ខណ្ឌ Town/District/Khan | ខេត្ត/រាជធានី Province/City | ទូរស័ព្ទលេខ Telephone N°

1

# វិក្កយបត្រអាករ
# TAX INVOICE

3

**អតិថិជន / Customer :**

ឈ្មោះក្រុមហ៊ុន ឬអតិថិជន
Company name / Customer ------------------------------------

ទូរស័ព្ទលេខ
Telephone N° ------------------------------------

**លេខអត្តសញ្ញាណកម្ម អតប (VATTIN)** □□□□-□□□□□□□□□ (ប្រសិនជាមាន / If any)

2

លេខរៀងវិក្កយបត្រ៖
Invoice N° ------------------------

កាលបរិច្ឆេទ៖
Date □□ □□ □□□□

4

| ល.រ N° | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |
| 7 | | | | |
| 8 | | | | |
| 9 | | | | |
| 10 | | | | |
| 11 | | | | |
| 12 | | | | |
| 13 | | | | |
| 14 | | | | |
| 15 | | | | |

| | |
|---|---|
| សរុប Sub Total | |
| អាករលើតម្លៃបន្ថែម ១០% VAT (10%) | |
| សរុបរួម Grand Total | |

5

ខ្មែរ 1 Sample only

ហត្ថលេខា និងឈ្មោះអ្នកទិញ
**Customer's Signature & Name**

ហត្ថលេខា និងឈ្មោះអ្នកលក់
**Seller's Signature & Name**

**សម្គាល់៖** ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
**Note:** Original invoice for customer , copied invoice for seller

របសញ្ញាលស់ក្រុមហ៊ុន
LOGO

# ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ

## COMPANY NAME

លេខអត្តសញ្ញាណកម្ម អតប (VATTIN) ☐☐☐☐-☐☐☐☐☐☐☐☐☐

អាសយដ្ឋាន៖ ផ្ទះលេខ Address Nº ផ្លូវ Street ឃុំ/សង្កាត់ Commune/Sangkat

ក្រុង/ស្រុក/ខណ្ឌ Town/District/Khan ខេត្ត/រាជធានី Province/City ទូរស័ព្ទលេខ Telephone Nº

1

# វិក្កយបត្រ
# INVOICE

2

លេខរៀងវិក្កយបត្រ៖ Invoice Nº ------------------

កាលបរិច្ឆេទ៖ Date ☐☐ ☐☐ ☐☐☐☐

3

**អតិថិជន / Customer :**

ឈ្មោះក្រុមហ៊ុន ឬអតិថិជន Company name / Customer ------------------

ទូរស័ព្ទលេខ Telephone Nº ------------------

4

| ល.រ Nº | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |
| 7 | | | | |
| 8 | | | | |
| 9 | | | | |
| 10 | | | | |
| 11 | | | | |
| 12 | | | | |
| 13 | | | | |
| 14 | | | | |
| 15 | | | | |
| | | សរុប (រួមបញ្ចូលទាំងអាករ) Total (VAT included) | | |

5

គំរូ 2 Sample only

ហត្ថលេខា និងឈ្មោះអ្នកទិញ
**Customer's Signature & Name**

ហត្ថលេខា និងឈ្មោះអ្នកលក់
**Seller's Signature & Name**

**សម្គាល់៖** ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់

**Note:** Original invoice for customer , copied invoice for seller



LOGO
ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ
COMPANY NAME
លេខអត្តសញ្ញាណកម្ម អតប (VATTIN)
1
អាសយដ្ឋាន៖ ផ្ទះលេខ Address N°
ផ្លូវ Street
ឃុំ/សង្កាត់ Commune/Sangkat
ក្រុង/ស្រុក/ខណ្ឌ Town/District/Khan
ខេត្ត/រាជធានី Province/City
ទូរស័ព្ទលេខ Telephone N°
វិក្កយបត្រអាករ
TAX INVOICE
3
អតិថិជន / Customer :
ឈ្មោះក្រុមហ៊ុន ឬអតិថិជន Company name / Customer
ទូរស័ព្ទលេខ Tel N°
លេខអត្តសញ្ញាណកម្ម អតប (VATTIN)
(ប្រសិនជាមាន / If any)
2
លេខរៀងវិក្កយបត្រ Invoice N°
កាលបរិច្ឆេទ Date
ល.រ N°
បរិយាយមុខទំនិញ Description
បរិមាណ Quantity
ថ្លៃឯកតា Unit Price
ថ្លៃទំនិញ Amount
4
Sample only
សរុប Sub Total
អាករលើតម្លៃបន្ថែម ១០% VAT (10%)
សរុបរួម Grand Total
5
ហត្ថលេខា និងឈ្មោះអ្នកទិញ Customer's Signature & Name
ហត្ថលេខា និងឈ្មោះអ្នកលក់ Seller's Signature & Name
សម្គាល់៖ ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
Note: Original invoice for customer , copied invoice for seller

LOGO

# ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ
## COMPANY NAME

1

លេខអត្តសញ្ញាណកម្ម អតប (VATTIN) ☐☐☐☐-☐☐☐☐☐☐☐☐☐

| អាសយដ្ឋាន៖ Address | ផ្ទះលេខ N° | ផ្លូវ Street | ឃុំ/សង្កាត់ Commune/Sangkat | ក្រុង/ស្រុក/ខណ្ឌ Town/District/Khan | ខេត្ត/រាជធានី Province/City | ទូរស័ព្ទលេខ Telephone N° |
|---|---|---|---|---|---|---|

## វិក្កយបត្រ
## INVOICE

3

**អតិថិជន / Customer :**

ឈ្មោះក្រុមហ៊ុន ឬអតិថិជន
Company name / Customer ---------------------------------------

ទូរស័ព្ទលេខ
Tel N° ---------------------------------------

2

លេខរៀងវិក្កយបត្រ
Invoice N° ---------------

កាលបរិច្ឆេទ៖
Date ☐☐ ☐☐ ☐☐☐☐

4

| ល.រ N° | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|

គំរូ 4
Sample only

សរុប (បូកបញ្ចូលទាំងអាករ)
**Total (VAT included)** ____________

5

ហត្ថលេខា និងឈ្មោះអ្នកទិញ
**Customer's Signature & Name**

ហត្ថលេខា និងឈ្មោះអ្នកលក់
**Seller's Signature & Name**

**សម្គាល់៖** ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
**Note:** Original invoice for customer , copied invoice for seller

អគ្គនាយកដ្ឋាន ពន្ធដារ